ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ១៧៣៣ អយក.ហវ

ថ្ងៃព្រហស្បតិ៍ ១១រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០២៤

## ជម្រាបជូន
## លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

**កម្មវត្ថុ៖** ការអនុវត្តថវិកាគាំទ្រ ដល់ការិយាល័យអប់រំ យុវជន និងកីឡា ដែលប្រើប្រាស់ឥណទាន របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

**យោង៖**-ការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

-លិខិតលេខ ៧៧៧២ សហវ.លស.អថ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោក លោកស្រី ប្រធាន** ជ្រាបថា៖ អនុលោមតាមខ្លឹមសារលិខិតលេខ ៧៧៧២សហវ.លស.អថ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដើម្បីពង្រឹងតម្លាភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវ ក្នុងការអនុវត្តថវិកាគាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រសួងអប់រំ យុវជន និងកីឡា សូមណែនាំដូចខាងក្រោម៖

១.មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តត្រូវផ្ទេរសាច់ប្រាក់ ជូនការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌតាមប្រព័ន្ធធនាគារ។

២.ចំពោះការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌណា ដែលគណនីធនាគារមិនដំណើរការ សូមសម្របសម្រួលជាមួយបុគ្គលិកធនាគារ ដើម្បីបើកឱ្យដំណើរវឡើងវិញ។

៣.ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ រួមមាន៖ ប័ណ្ណចំណូល ប័ណ្ណចំណាយ បញ្ជីបេឡា និងបញ្ជីតាមដានសាច់ប្រាក់នៅធនាគារ។

៤.ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវរៀបចំរបាយការណ៍ចំណាយថវិកាភ្ជាប់ជាមួយឯកសារគាំទ្រច្បាប់ដើម ជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងត្រូវថតចម្លងមួយច្បាប់រក្សាទុកនៅអង្គភាពសាមី សម្រាប់ជាកម្មវត្ថុសវនកម្មក្រោយចំណាយ។

៥.មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវប្រមូលរបាយការណ៍ទូទាត់ និងឯកសារគាំទ្រពីការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌដើម្បីទូទាត់ជម្រះបញ្ជីនិង/ឬបំពេញបេឡាឡើងវិញជាមួយរតនាគាររាជធានី ខេត្ត។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ប្រធាន ចាត់ចែងអនុវត្តប្រកបដោយគណនេយ្យភាព និងទទួលបានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រី ប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
" ដើម្បីជ្រាបជាព័ត៌មាន "
-កាលប្បវត្តិ
-ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ